## កបិលមហាព្រហ្ម នឹង ធម្មបាល (ដកស្រង់ចេញពីព្រះរាជពិធីទ្វាទសមាស)

ក្នុងកាលដើមនៃភទ្ទកប្បនេះ មានបុរសម្នាក់ឈ្មោះ ធម្មបាលជាបុត្រសេដ្ឋី រៀនចេះចប់ត្រៃវេទ តាំងពីអាយុ៧ឆ្នាំ។ សេដ្ឋីសាងប្រាសាទឲ្យនៅជិតដើមជ្រៃធំមួយ។ ធម្មបាលកុមារចេះទាំងភាសាបក្សីទាំងពួងផង ហើយបានជាអាចារ្យសម្តែងមង្គលផ្សេងៗដល់មនុស្សទាំងពួង។ គ្រានោះ មនុស្សលោករមែងរាប់អានព្រះមហាព្រហ្ម នឹង កបិលមហាព្រហ្ម ថាជាអ្នកសម្តែងមង្គលដល់មនុស្សទាំងពួង។ កាលកបិលមហាព្រហ្មជ្រាបពត៌មាននោះ ក៏ចុះមកសួរបញ្ហានឹងធម្មបាល៣ខ សន្យាថាបើដោះប្រស្នាបានក្នុងវេលា៧ថ្ងៃនឹងកាត់ក្បាលបូជាធម្មបាលកុមារ បើដោះមិនបាននឹងកាត់ក្បាលធម្មបាលវិញ។

លុះកន្លង៦ថ្ងៃហើយក៏ធម្មបាលគិតប្រស្នានោះមិនឃើញ ដឹងខ្លួនថានឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្មជាប្រាកដ ដូច្នេះគួអញរត់ទៅពួនលាក់ខ្លួនឲ្យស្លាប់បង់ដោយខ្លួនឯង ទើបចុះពីប្រាសាទទៅដេកនៅក្រោមដើមត្នោតមួយគូ ដែលមានសត្វឥន្ទ្រីញីឈ្មោលនៅ។ វេលាយប់ ឥន្ទ្រីញីសួរឥន្ទ្រីឈ្មោលថាព្រឹកស្អែកនេះយើងបានអាហារស្អី? ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងបានសាច់ធម្មបាលកុមារដែលត្រូវកបិលមហាព្រហ្មសម្លាប់ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រីញីសួរថាប្រស្នានោះដូចម្តេច? ឥន្ទ្រីឈ្មោលឆ្លើយថាវេលាព្រឹកសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅមុខ ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលប់មុខ។ ខមួយទៀតថាថ្ងៃត្រង់សិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅទ្រូង ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលាងទ្រូង។ ខមួយទៀតថាវេលាល្ងាចសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅជើង ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលាងជើង។ ធម្មបាលកុមារបានឮដូច្នោះក៏ត្រឡប់ទៅប្រាសាទវិញ។ ព្រឹកឡើង ធម្មបាលកុមារក៏ឆ្លើយដោះស្រាយតាមដែលបានឮមក ទើបកបិលមហាព្រហ្មហៅបុត្រីទាំង៧នាក់មកប្រាប់ថាឥឡូវបិតាត្រូវកាត់ក្បាលបូជាធម្មបាលកុមារតែបើដាក់ក្បាលនោះលើផែនដីក៏នឹងកើតជាភ្លើងឆេះលោកធាតុ បើបោះទៅលើអាកាស ភ្លៀងក៏នឹងរាំង បើបោះទៅក្នុងមហាសមុទ្រ ទឹកក៏រីងស្ងួតអស់ ដុច្នេះសុំឲ្យកូនទាំង៧នាក់យកពានមាសមកទទួលក្បាល ថាហើយក៏កាត់ក្បាលហុចទៅនាងទុង្សាជាកូនច្បង ទើបនាងទុង្សាយកពានចូលទៅទទួលក្បាលបិតា ហើយហែប្រទក្សិណភ្នំព្រះសុមេរ៉ុ៦០នាទីហើយក៏អញ្ជើញទៅប្រតិស្ឋានទុកក្នុងមណ្ឌបនៅក្នុងគុហាគន្ធមាលី ភ្នំកៃលាស។ ព្រះវិស្សកម្មក៏និម្មិតរោងហៅ "ភគវតីសភា" ជាទីប្រជុំទេវតា លុះដល់គម្រប់ ១ឆ្នាំសង្ក្រាន្តនាងទេពធីតាទាំង៧ផ្លាស់គ្នាមកអញ្ជើញក្បាលកបិលមហាព្រហ្មចេញមកហែប្រទក្សិណភ្នំព្រះសុមេរ៉ុរាល់ៗឆ្នាំហើយត្រឡប់ទៅទេវលោកវិញ។

ឈ្មោះទេពធីតាដែលត្រូវវេនចុះមកអញ្ជើញក្បាលកបិលមហាព្រហ្ម គឺទៅតាមថ្ងៃចូលឆ្នាំ បើ :

- ❖ ថ្ងៃអាទិត្យ ឈ្មោះទុង្សា សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ (ពណ៌ក្រហម) ភក្សាហារផ្លែឧទុម្ពរ អាវុធស្តាំច័ក្រ អាវុធឆ្វេងស័ង្ខ ពាហនៈគ្រុឌ ។
- ❖ ថ្ងៃចន្ទ ឈ្មោះគោរាគ សៀតផ្កាអង្គាបុស្ប គ្រឿងប្រដាប់មុក្តា (គជ់ខ្យង) ភក្សាហារប្រេង អាវុធស្តាំព្រះខ័ន ឆ្វេងឈើច្រត់ ពាហនៈខ្លា ។
- ❖ ថ្ងៃអង្គារ ឈ្មោះរាក្សសា សៀតផ្កាឈូក គ្រឿងប្រដាប់មោរា (កែវសម្បុរឆ្នូត) ភក្សាហារលោហិត អាវុធស្តាំត្រីសូល៍ ឆ្វេងធ្នូ ពាហនៈអស្សតរ (សេះ) ។
- ❖ ថ្ងៃពុធ ឈ្មោះមណ្ឌា សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះសប្បិ (ទឹកដោះថ្លា) អាវុធស្តាំម្ជុល ឆ្វេងឈើច្រត់ ពាហនៈលា ។
- ❖ ថ្ងៃព្រហស្បតិ៍ ឈ្មោះកិរិណី សៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែក ល្ង អាវុធស្តាំកង្វេរ ឆ្វេងកាំភ្លើង ពាហនៈដំរី។
- ❖ ថ្ងៃសុក្រ ឈ្មោះកិមិរា សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្បរាគ័ម (ពណ៌លឿង) ភក្សាហារចេកណាំវ៉ា អាវុធស្តាំព្រះខ័ន ឆ្វេងពិណ ពាហនៈក្របី ។

❖ ថ្ងៃសៅរ៍ ឈ្មោះមហោទរា សៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ អាវុធស្នាំច័ក្រ ឆ្វេងត្រីសូល៍ ពាហនៈក្ងោក ។

ទេពធិតាសុទ្ធតែសម្ដែងកិរិយាផ្សេងៗដូចនេះ ៖

ពី ព្រលឹម ដល់ ថ្ងៃត្រង់ ជិះឈរលែងដៃ

ពី ថ្ងៃត្រង់ ដល់ ព្រលប់ អង្គុយពាក់ចៀង

ពី ព្រលប់ ដល់ អាធ្រាត្រ ដេកបើកភ្នែក

ពី អាធ្រាត្រ ដល់ ភ្លឺ ដេកធ្មេចភ្នែក

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*